**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ៦៧. សសរ**

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការដេញថ្លៃកំរោងផ្លូវជាតិលេខ ៣ ពីទីរួមខេត្តកំពតទៅត្រពាំងរពៅ
៚៚៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១ :** បង្កើតគណៈកម្មការដេញថ្លៃគំរោងផ្លូវជាតិលេខ ៣ ពីទីរួមខេត្តកំពតទៅត្រពាំងរពៅ ដែលមានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **អ៊ុក ចាន់** | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២-ឯកឧត្តម | **វង្សី វិស្សុត** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣-ឯកឧត្តម | **ឈិន គង់ហ៊ាន** | អគ្គនាយកនៃនាយកដ្ឋានសាធារណៈការនិងដឹកជញ្ជូន | សមាជិក |
| ៤-លោក | **ទាវ ស៊ីមសុរិយា** | ប្រធាននាយកដ្ឋានផែនការ ក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៥-បណ្ឌិត | **ជា វ៉ាន់ដេត** | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ គ.រ.ម. | សមាជិក |
| ៦-លោក | **ង៉ោ យុនថា** | ប្រធានការិយាល័យសហប្រតិបត្តិការទ្វេភាគី ស.ហ.វ. | សមាជិក |

**ប្រការ២ :** គណៈកម្មការមានភារកិច្ចប្រកាសដេញថ្លៃជ្រើសរើសក្រុមហ៊ុនស្ថាបនាផ្លូវជាតិលេខ ៣ ពីទីរួមខេត្តកំពតទៅត្រពាំងរពៅ ក្រោមហិរញ្ញប្បទាននៃឥណទានសម្បទានរបស់រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ ។

**ប្រការ៣ :** រាល់ទំនាក់ទំនងរវាងភាគីកម្ពុជានិងភាគីកូរ៉េ ត្រូវធ្វើឡើងតាមរយៈប្រធានគណៈកម្មការ ។ រាល់បទប្បញ្ញត្តិនានា ដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងសាមីខ្លួន ដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៣*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ✓
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ